ISSN 1560-7615 / ISBN 978-99950-52-06-5

# ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ១៤ លេខ៣ | កក្កដា - កញ្ញា ឆ្នាំ២០១០ | តម្លៃ ១.៥០០រ

20
ខួបលើកទី
CDRI 1990-2010

## សិក្សាពីកត្តាកំណត់លើជោគជ័យ នៃប្រព័ន្ធគ្រប់គ្រងធារាសាស្ត្រដោយកសិករ៖ ករណីសិក្សា នៅខេត្តកំពង់ស្ពឺ[១]

*អ្នកដឹកនាំសហគមន៍ម្នាក់នៅខេត្តកំពង់ស្ពឺ និយាយថា "ក្នុងនាមជាអ្នកដឹកនាំ យើងមិនអាចសម្រេចចិត្តធ្វើការងារដោយមិនបានពិភាក្សាជាមួយកសិករឡើយ បើមិនដូច្នោះទេ យើងនឹងត្រូវធ្វើការនោះតែម្នាក់ឯង" ។*



*ទឹកស្រោចស្រពគ្រប់គ្រាន់ ដំណាំលូតលាស់ល្អ កសិករសប្បាយចិត្ត ខេត្តកំពង់ស្ពឺ*

### សេចក្តីផ្តើម

និន្នាការសាកលលើការអភិរក្សធនធានធម្មជាតិនាពេលបច្ចុប្បន្ន បានកំណត់យកតួនាទីរបស់អ្នកប្រើប្រាស់ថាជាដំណោះស្រាយ ជាជាងបញ្ហាចោទ ។ ចំណុចនេះបានត្រួសត្រាយផ្លូវសំរាប់វិធីសាស្ត្រថ្មីនៃការបែងចែកឡើងវិញនូវសិទ្ធិអំណាចគ្រប់គ្រងជាលក្ខណៈមជ្ឈការ ទៅឲ្យក្រុមប្រជាជនក្នុងសហគមន៍ ដើម្បីឲ្យមានការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព (Gibson etal.2000) ។វិធីសាស្ត្របែបនេះក៏ឃើញមានជាក់ស្ដែងនៅកម្ពុជាដែរ ។ នៅក្រោមកំណែទម្រង់វិមជ្ឈការ បន្ទាប់ពីការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់លើកទី១ ក្នុងឆ្នាំ២០០២មក រដ្ឋាភិបាលបានផ្ទេរសិទ្ធិអំណាចមួយភាគ ក្នុងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រពីក្រសួងធនធានទឹក និងឧតុនិយម (MoWRAM) ឲ្យទៅសហគមន៍កសិករប្រើប្រាស់ទឹក (FWUCs) ។ FWUCs ទទួលខុសត្រូវលើការងារគ្រប់គ្រង និងថែទាំ ប្រព័ន្ធធារាសាស្ត្រក្នុងតំបន់របស់ខ្លួន ដោយឡែកការថែទាំទ្រង់ទ្រាយធំ គឺនៅតែស្ថិតក្រោមការទទួលខុសត្រូវរបស់រដ្ឋាភិបាលដដែល ។

ដំណើរការ FWUCs ត្រូវប្រឈមនឹងបញ្ហាចោទជាច្រើន ជាពិសេសក្នុងបរិបទនៃ ប្រទេសដែលមានអត្រាភាពក្រីក្រខ្ពស់ ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រទ្រុឌទ្រោម ដែលបន្សល់ពីជំនាន់ប៉ុល ពត (Perera 2006) សង្គមស៊ីវិលទន់ខ្សោយ និងវិមជ្ឈការកំពុងដំណើរការ (Kim & Öjendal 2007) ។ ករណីសិក្សាពី FWUC មួយក្នុងខេត្តកំពង់ឆ្នាំង រកឃើញថា សហគមន៍ពុំសូវដំណើរការល្អ ដោយសារខ្វះការចូលរួមពីកសិករ ភាពជាម្ចាស់កម្មសិទ្ធិលើប្រព័ន្ធធារាសាស្ត្រ និងសិទ្ធិអំណាចគ្រប់គ្រង (Chea

១ អត្ថបទនេះ រៀបរៀងដោយ រស់ បណ្ដែត អ្នកស្រាវជ្រាវ នៃវិទ្យាស្ថាន CDRI ។ អត្ថបទនេះ ផ្អែកលើសារណាបញ្ចប់ថ្នាក់អនុបណ្ឌិត (MApplSc) ឆ្នាំ២០១០ របស់អ្នកនិពន្ធស្ដីពី "ការគ្រប់គ្រងការស្រោចស្រពដោយមានការចូលរួម និងកត្តាជះឥទ្ធិពលលើជោគជ័យនៃសហគមន៍កសិករប្រើប្រាស់ទឹក៖ ករណីសិក្សានៅប្រទេសកម្ពុជា" ។

## មាតិកា

សិក្សាពីកត្តាជះឥទ្ធិពលលើជោគជ័យនៃប្រព័ន្ធស្រោចស្រព គ្រប់គ្រងដោយកសិករ៖ ករណីសិក្សានៅកំពង់ស្ពឺ ........១
ការវាយតម្លៃឆាប់រហ័សពីផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច មកលើក្រុមគ្រួសារកម្ពុជា និងពលករខាយរងគ្រោះ ...៦
មនុស្សវ័យចំណាស់គាំទ្រកម្មវិធីព្យាបាលដោយឱសថប្រឆាំងវីរុសអេដស៍ នៅខេត្តបន្ទាយមានជ័យ..........១០
តាមដានសេដ្ឋកិច្ច – ស្ថានភាពក្រៅប្រទេស...............១៥
– ស្ថានភាពក្នុងប្រទេស ............... ១៧
ព័ត៌មានថ្មីៗពី វិទ្យាស្ថាន CDRI .....................................២៤

រូបភាព ១៖ កត្តានាំទៅរកភាពជោគជ័យនៃសហគមន៍កសិករប្រើប្រាស់ទឹក អូត្រែង




forthcoming) ។ នៅខេត្តតាកែវ បរាជ័យនៃ FWUCs ទំនង ផុសចេញពី កង្វះធនធានហិរញ្ញវត្ថុ ភាពអន់ខ្សោយក្នុងការដឹកនាំ និងកង្វះការលើកទឹកចិត្ត និង អន្តរាគមន៍ពីក្រុមប្រឹក្សាឃុំ (Thun 2008) ។

បើទោះជាយ៉ាងនេះក្ដី មាន FWUCs ខ្លះ ដែលទទួលបានជោគជ័យក្នុងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ។[2] ការសិក្សានេះ ជួយបំពេញបន្ថែមលើការសិក្សាពីមុនៗ ដោយពិនិត្យពីកត្តានានាដែលជះឥទ្ធិពលដល់ជោគជ័យរបស់ FWUCs ដើម្បីព្យាយាមកែលំអ និងលើកកំពស់ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រមួយចំនួនដែលមិនសូវជោគជ័យ ។ ការសិក្សានេះបានជ្រើសយកសហគមន៍កសិករប្រើប្រាស់ទឹកអូរត្រែង ដែល MoWRAM បានចាត់ទុកថា មានជោគជ័យខ្លាំងជាងគេ នៅឆ្នាំ២០០៨ មកសិក្សា ។ សហគមន៍នេះស្ថិតក្នុង ឃុំជង្រុក និងឃុំព្រៃញាតិ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដែលកន្លងមកសហគមន៍បានជួយកែលំអជីវភាពប្រជាកសិករ និងដំណើរការដោយខ្លួនឯងក្នុងការងារគ្រប់គ្រង និងថែទាំប្រព័ន្ធធារាសាស្ត្រ ប្រចាំថ្ងៃរបស់ខ្លួន ។

## លទ្ធផលការស្រាវជ្រាវ

មានកត្តាផ្ទៃក្នុង ៥ និងកត្តាខាងក្រៅ ២ ដែលនាំឲ្យសហគមន៍អូរត្រែង ទទួលបានជោគជ័យ ។ កត្តាផ្ទៃក្នុង រួមមាន៖ (១) ការចូលរួមរបស់កសិករ (២) ការគ្រប់គ្រង និងអភិបាលកិច្ចនៅមូលដ្ឋាន (៣) ផលប្រយោជន៍ពីប្រព័ន្ធ (៤) គុណភាពហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ និង (៥) ចរិតលក្ខណៈ និងស្ថានភាពរស់នៅជាក្រុម របស់កសិករជាសមាជិក ។ កត្តាខាងក្រៅ គឺមានជំនួយគាំទ្រពីខាងក្រៅ និងទីផ្សារ ។ ក្រាហ្វិក ១ បង្ហាញពី ទំនាក់ទំនងទៅមករវាងកត្តាទាំងប្រាំពីរ ។

**ការចូលរួមរបស់កសិករ៖** កសិករបានចូលរួមសកម្មក្នុងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ដែលរួមមាន ការចូលរួមវិភាគទានជាប្រាក់កាស កំលាំងពលកម្ម និងធនធានដទៃទៀត ព្រមទាំងការចូលរួមធ្វើសេចក្ដីសម្រេចចិត្ត ។ ការចូលរួមមាន ៤ ប្រភេទគឺ៖ ការបង់ថ្លៃសេវាប្រើប្រាស់ទឹក ការងារចែកចាយទឹក ការថែទាំប្រព័ន្ធប្រឡាយ និងទំនប់ និងការជួបប្រជុំសហគមន៍ ។

ការចូលរួមរបស់កសិករសំខាន់ណាស់ ព្រោះជះឥទ្ធិពលទៅលើគុណភាពនៃប្រព័ន្ធធារាសាស្ត្រ អភិបាលកិច្ច និងការគ្រប់គ្រងរបស់គណៈកម្មការ ។ ការបង់ថ្លៃសេវាប្រើប្រាស់ទឹក ធានាធនធានហិរញ្ញវត្ថុសំរាប់ដំណើរការប្រព័ន្ធ ដែលធ្វើឲ្យសហគមន៍មិនសូវពឹងផ្អែកលើជំនួយគាំទ្រពីខាងក្រៅ ។ ការចូលរួមក្នុងការងារចែកចាយទឹក ធានាដល់ការផ្គត់ផ្គង់ទឹកឲ្យកសិករបានគ្រប់គ្រាន់ និងទាន់ពេល និងជួយកាត់បន្ថយបន្ទុកការងាររបស់គណៈកម្មការ ដែលធ្វើឲ្យពួកគាត់បន្តការងារនៅក្នុងសហគមន៍ ។ ម្យ៉ាងទៀត កាលណាកសិករចូលរួមក្នុងការងារចែកចាយទឹក នោះសហគមន៍ទំនងជាមិនសូវជួបប្រទះ បញ្ហាទឹកជន់លិចដំណាំ

---

២ សម្ភាសន៍ជាមួយបុគ្គលិក នៃ MoWRAM កាលពីថ្ងៃទី ៣ តុលា ២០០៨ ។

ទឹកហៀរចោល ឬការខ្វះខាតទឹកសហគមន៍ជាដើម ។ ការចូលរួមពីប្រជាជនមូលដ្ឋានក្នុងការងារថែទាំ ដូចជា រាយការណ៍ពីការខូចខាត និងចូលរួមវិភាគទានជាកំលាំងពលកម្ម និង/ឬ ប្រាក់កាសក៏អាចជួយកាត់បន្ថយបន្ទុកការងាររបស់គណៈកម្មការ ក្នុងការត្រួតពិនិត្យ និងដើរល្បាត និងជួយកែលំអគុណភាពហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រផងដែរ ។ ការចូលរួមប្រជុំក្នុងសហគមន៍ ជួយបង្កើនការយល់ដឹងពីសារៈសំខាន់ នៃការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ បង្កើនភាពជាម្ចាស់លើការសម្រេចចិត្ត តម្លាភាព និងទំនុកចិត្តរវាងគណៈកម្មការ និងកសិករ ហើយទាំងអស់នេះនាំឲ្យមានការចូលរួមកាន់តែច្រើនពីសំណាក់កសិករ ក្នុងការងារគ្រប់គ្រង និងអភិបាលកិច្ចធារាសាស្ត្រ ។

**ការគ្រប់គ្រង និងអភិបាលកិច្ចមូលដ្ឋាន៖** កត្តានេះក៏សំខាន់ណាស់ដែរ ព្រោះជានាំឲ្យមានការចូលរួមពីកសិករ បង្កើនផលប្រយោជន៍ពីធារាសាស្ត្រ លើកកំពស់គុណភាពហេដ្ឋារចនាសម្ព័ន្ធ និងបង្កើនជំនួយគាំទ្រពីខាងក្រៅ ។ សមាសធាតុនៃការគ្រប់គ្រង និងអភិបាលកិច្ចមូលដ្ឋាន រួមមាន រចនាសម្ព័ន្ធសហគមន៍ សមត្ថភាពដឹកនាំរបស់គណៈកម្មការ របៀបនៃការបង្កើតសហគមន៍ និងការអនុវត្ត ការពង្រឹង និងកែសម្រួលលក្ខន្តិកៈរបស់គណៈកម្មការ ។

ក. រចនាសម្ព័ន្ធសហគមន៍ មានបីថ្នាក់៖ គណៈកម្មការ ក្រុម និងអនុក្រុម ។ រចនាសម្ព័ន្ធនេះដំណើរការបានល្អ ព្រោះវាធ្វើឲ្យភូមិនីមួយៗ ទទួលខុសត្រូវលើការងារគ្រប់គ្រង និងថែទាំហេដ្ឋារចនាសម្ព័ន្ធដែលផ្គត់ផ្គង់ទឹកដល់ពួកគេ ។ រចនាសម្ព័ន្ធនេះ ក៏ជួយសម្រួលឲ្យអនុក្រុមនីមួយៗមាន សមាជិកភាពតិចនាក់ ដែលធ្វើឲ្យគណៈកម្មការងាយស្រួលធ្វើការពង្រឹងលក្ខន្តិកៈរបស់សហគមន៍ ។

ខ. សមត្ថភាពដឹកនាំចែកជា៖ (១) ឥរិយាបថ (២) ចំណេះដឹង និងជំនាញ និង(៣) សិទ្ធិអំណាច ។ ឥរិយាបថដែលកសិករសំគាល់ថាជាអ្នកដឹកនាំល្អ រួមមាន សីលធម៌ការងារល្អ ការប្តេជ្ញាចិត្តខិតខំធ្វើការងារ ភាពស្មោះត្រង់ តម្លាភាព និងឆន្ទៈគិតគូរពីផលប្រយោជន៍សហគមន៍ជាធំ ការធ្វើការងារទន្ទឹមគ្នានឹងកសិករ ភាពទំនួលខុសត្រូវ និងការបន្តរៀនសូត្របន្ថែមលើការងារគ្រប់គ្រងធារាសាស្ត្រ ។ កសិករក៏បានកំណត់ដែរថា ចំណេះដឹង និងជំនាញសំខាន់ៗរបស់គណៈកម្មការរួមមាន ការយល់ដឹងពីរបៀបគ្រប់គ្រងប្រព័ន្ធ ការចេះលើកទឹកចិត្ត និងសមត្ថភាពដោះស្រាយបញ្ហាប្រកបដោយភាពច្នៃប្រឌិត ។ គណៈកម្មការក៏គួរមានជំនាញក្នុងការងារបង្រួបបង្រួម ការបែងចែកតួនាទី និងការទំនាក់ទំនងផងដែរ ។ ដោយឡែកសិទ្ធិអំណាចរបស់គណៈកម្មការ សំដៅលើការទទួលខុសត្រូវ និងអំណាចក្នុងការកៀងគរកសិករ និងការគ្រប់គ្រងសហគមន៍ ។

សមត្ថភាពដឹកនាំរបស់គណៈកម្មការដែលផ្អែកលើ តម្លាភាព និងភាពស្មោះត្រង់ រួមចំណែកដល់ជោគជ័យរបស់សហគមន៍ ដោយធានាឲ្យកសិករមានទំនុកចិត្តលើគណៈកម្មការ ។ ដោយសារសីលធម៌ការងារល្អរបស់ខ្លួន គណៈកម្មការទទួលបានការគោរពរាប់អានពីកសិករ ។ ទំនុកចិត្ត និងការគោរពនេះ ធ្វើឲ្យគណៈកម្មការមានប្រជាប្រិយភាពក្នុងចំណោមកសិករ ដែលកាន់តែធ្វើអោយកសិករពេញចិត្តចូលរួមក្នុងសកម្មភាពសហគមន៍ថែមទៀត ។

ចំណេះដឹង និងជំនាញក្នុងការងារគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រក៏ធ្វើឲ្យកសិករមានទំនុកចិត្ត និងចូលរួមសកម្មដែរ ។ ថ្នាក់ដឹកនាំដែលមានជំនាញទំនាក់ទំនង ក៏អាចស្នើសុំ ជំនួយទ្រទ្រង់ពីខាងក្រៅ ។ លើសពីនេះ ដោយសារគណៈកម្មការមានសិទ្ធិសម្រេចលើការងារគ្រប់គ្រងធារាសាស្ត្រ ដោយពុំសូវមានការជ្រៀតជ្រែកពី MoWRAM ឬអាជ្ញាធរមូលដ្ឋាន ដូច្នេះពួកគាត់អាចធ្វើការថែទាំ និងឆ្លើយតបតាមសំណើសុំរបស់កសិករបានទាន់ពេលវេលា ។ សិទ្ធិអំណាចនេះក៏អាចឲ្យគណៈកម្មការធ្វើការពង្រឹងលក្ខន្តិកៈ និងធ្វើឲ្យគណៈកម្មការ និងកសិករមានភាពជាម្ចាស់លើការសម្រេចចិត្តផងដែរ ។

គ. សហគមន៍ ត្រូវបានរៀបចំឡើងតាមគោលការណ៍ប្រជាធិបតេយ្យ ដោយកសិករអាចបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំដែលខ្លួនពេញចិត្ត និងរៀបចំបង្កើតលក្ខន្តិកៈសំរាប់គ្រប់គ្រងប្រព័ន្ធដោយខ្លួនឯង ។ ចំណុចនេះ ធ្វើឲ្យកសិករពេញចិត្តអនុវត្តតាមលក្ខន្តិកៈ ហើយសហគមន៍ក៏អាចជ្រើសរើសគណៈកម្មការដែលមានសមត្ថភាពដឹកនាំខ្ពស់ ព្រោះកសិករនឹងបោះឆ្នោតឲ្យថ្នាក់ដឹកនាំណាដែលពួកគេគិតថា អាចត្រួតត្រា និងគ្រប់គ្រងសហគមន៍ប្រកបដោយប្រសិទ្ធភាព ។

ឃ. សហគមន៍អនុវត្តលក្ខន្តិកៈលើ វិធាន ៤ចំនុចសំខាន់ៗ៖ (១) ការបែងចែកទឹក (២) ការថែទាំប្រព័ន្ធធារាសាស្ត្រ (៣) ការប្រមូលថ្លៃសេវាប្រើប្រាស់ទឹក និង (៤) ការគ្រប់គ្រងហិរញ្ញវត្ថុ ។ ការធ្វើសេចក្តីសម្រេចចិត្តលើការអនុវត្តលក្ខន្តិកៈនេះផ្អែកលើលក្ខណៈវិនិច្ឆ័យចំនួន ៦ គឺ៖ ការស្រុះស្រួលគ្នា ការបញ្ចូលគំនិតយោបល់គ្នា ការឆ្លើយតប ប្រសិទ្ធភាព តម្លាភាព និងភាពយុត្តិធម៌ ។ ចំណុចទាំងនេះធានាឲ្យទំនាស់ថយចុះ កសិករមានភាពជាម្ចាស់លើសេចក្តីសម្រេចចិត្ត កសិករគោរពលក្ខន្តិកៈ សហគមន៍ទទួលបានធនធានហិរញ្ញវត្ថុសំរាប់ដំណើរការប្រព័ន្ធ ការផ្គត់ផ្គង់ទឹកប្រកបដោយប្រសិទ្ធភាព និងសំខាន់បំផុតធានាឲ្យកសិករមានទំនុកចិត្តលើគណៈកម្មការ ។

ង. ការពង្រឹងលក្ខន្តិកៈ ពោលគឺ ការពិន័យជនដែលប្រព្រឹត្តិខុសតែងបានធ្វើឡើងជារឿយៗ ក្នុងការងារបែងចែកទឹករបស់សហគមន៍ ។ មានតែកសិករដែលបានដាក់សំណើ និងទទួលការយល់ព្រមពីគណៈកម្មការប៉ុណ្ណោះ ដែលអាចទទួលបានទឹកស្រោចស្រព រីឯអ្នកមិនបានអនុវត្តតាមវិធាននេះមិនអាចទទួលបានទឹកឡើយ ។ ការពង្រឹងលក្ខន្តិកៈយ៉ាងទៀងទាត់ជួយកាត់បន្ថយករណីលួចទឹក ធានាឲ្យមានយុត្តិធម៌ក្នុងចំណោមសមាជិក និងជំរុញការចូលរួមកាន់តែច្រើន ។

ច. លក្ខន្តិកៈត្រូវបានកែសម្រួលនៅពេល៖ (១) កសិករជួបប្រទះការខូចខាតផលដំណាំ (២) គណៈកម្មការមានបន្ទុកការងារច្រើន (៣) កសិករមានភាពរវល់នឹងការងារ (៤) បរិមាណទឹកប្រើប្រាស់ក្នុងប្រព័ន្ធមិនគ្រប់គ្រាន់ និង (៥) កំរិតនៃលទ្ធភាពទទួលបានទឹករបស់កសិករមានតិច ។ គណៈកម្មការបានកែសម្រួលលក្ខន្តិកៈលើ៤ចំណុច គឺ៖ (១) ការប្រមូលថ្លៃសេវាប្រើប្រាស់ទឹក (២) ទំនួលខុសត្រូវរបស់គណៈកម្មការ (៣) វត្តមានកសិករក្នុងការប្រជុំសហគមន៍ និងការងារថែទាំ និង (៤) ការបែងចែកទឹក ។ ការកែសម្រួលបែបនេះជួយបង្កើនភាពយុត្តិធម៌ក្នុងចំណោមកសិករ ទំនុកចិត្តរបស់កសិករលើគណៈកម្មការ និងការចូលរួម ។

**ផលប្រយោជន៍ពីប្រព័ន្ធ៖** នេះជាកត្តាលើកទឹកចិត្តចំបងបំផុតដែលជំរុញដល់ការចូលរួមរបស់កសិករ ។ ប្រព័ន្ធធារាសាស្ត្រអូរត្រែង ផ្ដល់ផលប្រយោជន៍ ២ បែបគឺ៖ បង្កើនសន្តិសុខស្បៀង និងចំណូលបន្ថែមជូនកសិករ ។ កសិករពឹងផ្អែកលើទឹកភ្លៀងដើម្បីដាំស្រូវនៅរដូវវស្សា ។ ដោយសារជារឿយៗភ្លៀងធ្លាក់មិនបានគ្រប់គ្រាន់ ដូច្នេះទឹកពីប្រព័ន្ធជួយបំពេញបន្ថែមទឹកភ្លៀងដែលជួយធានាឲ្យស្រូវវស្សាទទួលបានទិន្នផលខ្ពស់ ។ នៅឆ្នាំខ្លះកសិករប្រើប្រាស់ទឹកពីប្រព័ន្ធ ដើម្បីធ្វើការសាបព្រួស និងដកស្ទូង ហើយនៅឆ្នាំខ្លះទៀត ពួកគេត្រូវប្រើទឹកពីប្រព័ន្ធ រហូតដល់ពេលប្រមូលផលស្រូវតែម្ដង ។

កសិករភាគច្រើន យល់ថាកំណើនទិន្នផលស្រូវវស្សាគឺជាផលប្រយោជន៍ដ៏ចំបងមួយរបស់ពួកគេ ពីព្រោះប្រជាជនក្នុងសហគមន៍តែងធ្វើស្រូវវស្សាសម្រាប់ការហូបចុកផ្ទាល់ខ្លួន ។ ស្រូវវស្សាជាកត្តាធានាសន្តិសុខស្បៀងដល់ប្រជាជន ។ គ្រួសារខ្លះដែលពុំមានប្រភពចំណូលអ្វីផ្សេង បានលក់ស្រូវវស្សារបស់ខ្លួនមួយភាគ ដើម្បីដោះស្រាយការចំណាយផ្សេងៗ ។

ផលប្រយោជន៍មួយទៀត គឺចំណូលបានពីការលក់ផលដំណាំនៅរដូវប្រាំង ដូចជា ឪឡឹក ត្រឡាច ល្ពៅ ។ ដោយសារនៅរដូវប្រាំងមានភ្លៀងធ្លាក់តិចតួច ដូច្នេះកសិករត្រូវពឹងផ្អែកស្ទើរទាំងស្រុងលើទឹកពីប្រព័ន្ធ ។ មួយវិញទៀតគឺ ចំណូលបានពីផលដំណាំទាំងនេះ មានចំនួនស្មើនឹង ២ ទៅ ៤ដង នៃថ្លៃដើមគិតបញ្ចូលទាំងថ្លៃសេវាប្រើប្រាស់ទឹកស្រោចស្រពផង (តារាង ១) ។ ដូច្នេះផលដំណាំនៅរដូវប្រាំង ជាប្រភពចំណូលដ៏សំខាន់មួយរបស់កសិករ ។

ចំណូលខាងលើសំខាន់សំរាប់កសិករ ព្រោះនៅរដូវប្រាំងកសិករពុំសូវមានការងារធ្វើ ហើយកសិករក៏ខ្វះខាតជំនាញធ្វើការងារផ្សេងដែរ ។ បើទោះជាមានកសិករមួយចំនួននិយាយថា ពួកគាត់អាចរកការងារធ្វើបាននៅរដូវប្រាំង ការងារទាំងនោះមិនផ្ដល់ចំណូលច្រើនដូចការដាំដំណាំទេ ។

**គុណភាពនៃហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ** ជាកត្តាសំខាន់មួយ ។ ប្រព័ន្ធអូរត្រែងមានអាងស្តុកទឹកដ៏ធំ (២.៥៦៣.៧៥០ ម៉ែត្រគូប) សំរាប់រក្សាទឹកភ្លៀង ដែលបានសាងសង់ឡើងយ៉ាងល្អ ហើយពុំសូវមានការជ្រាបបាត់បង់ទឹកឡើយ ។ លក្ខណៈនេះ ធ្វើឲ្យប្រព័ន្ធអាចស្តុកទឹកបានគ្រប់គ្រាន់ សំរាប់ស្រោចស្រពនៅរដូវវស្សា និងសំរាប់ដំណាំនៅរដូវប្រាំង ។

ប្រព័ន្ធធារាសាស្ត្រនៅអូរត្រែងក៏មានប្រឡាយនិងទ្វារទឹកយ៉ាងច្រើនដែលកសាងបានយ៉ាងល្អ ។ កត្តានេះ ជួយឲ្យការចែកចាយទឹកមានប្រសិទ្ធភាពខ្ពស់ ។ ដោយសារប្រព័ន្ធអាចផ្គត់ផ្គង់ទឹកបានគ្រប់គ្រាន់ និងទាន់ពេលវេលា ដូច្នេះកសិករក៏ពេញចិត្តបង់ថ្លៃសេវាស្រោចស្រព ។

**ចរិតលក្ខណៈ និងស្ថានភាពរស់នៅជាក្រុមរបស់កសិករជាសមាជិក៖** (១) ទំហំសមាជិក (២) ភាពស្រដៀងគ្នាក្នុងការរស់នៅ (៣) ភាពពឹងផ្អែកលើការដាំដុះ និង (៤) ប្រពៃណីសហការគ្នាក្នុងការគ្រប់គ្រងធារាសាស្ត្រ ។ ដោយសារក្រុម និងអនុក្រុមកសិករ

តារាង ១៖ ឧទាហរណ៍ នៃចំណាយ និងចំណូល នៃផលិតកម្មដំណាំនៅរដូវប្រាំង ឆ្នាំ២០០៨

| ទំហំដី (ហិកតា) | ដំណាំ | ចំណាយសរុប (ដុល្លារ) (គិតទាំងថ្លៃទឹកស្រោចស្រព) | ចំណូលសរុប (ដុល្លារ) | ចំណូលសរុប (គិតជា % នៃចំណាយ) |
|---|---|---|---|---|
| 1.00 | ឪឡឹក | 75 | 500 | 769 |
| 0.30 | ឪឡឹក | 43 | 160 | 400 |
| 0.10 | ឪឡឹក | 64 | 125 | 198 |
| 0.35 | ត្រឡាច | 104 | 250 | 250 |
| 0.20 | ត្រឡាច | 152 | 300 | 200 |
| 0.15 | ត្រឡាច | 62 | 150 | 250 |
| 0.30 | ល្ពៅ | 43 | 150 | 375 |

មានទំហំសមាជិកតូច ដូច្នេះគណៈកម្មការអាចអនុវត្ត និងពង្រឹងលក្ខន្តិកៈសហគមន៍បានយ៉ាងស្រួល ។ ទំហំសមាជិកតូចក៏ជួយឲ្យកសិករមានទំនាក់ទំនងគ្នាជាញឹកញាប់ និងអនុញ្ញាតឲ្យពួកគេអាចពិនិត្យតាមដានគ្នាចុះឡើងលើការងារបែងចែកទឹកនិងការងារថែទាំប្រព័ន្ធ ។

កសិករក្នុងសហគមន៍ មានភាពស្រដៀងគ្នាគួរសមលើវប្បធម៌ ជាតិសាសន៍ តម្រូវការ របៀបធ្វើស្រែចំការ និងកំរិតជីវភាព ។ ជំនឿ ទស្សនៈ និងតម្រូវការ ប្រហាក់ប្រហែលគ្នា បានជួយសម្រួលដល់ កិច្ចសហប្រតិបត្តិការរបស់កសិករក្នុងការងារគ្រប់គ្រងប្រព័ន្ធ ។

ភាពពឹងផ្អែកខ្លាំងលើការដាំដុះ ធ្វើឲ្យកសិករយល់ថាប្រព័ន្ធធារាសាស្ត្រ មានសារៈសំខាន់សម្រាប់ជីវភាពរស់នៅរបស់ពួកគេ ដូច្នេះពួកគេចង់ចូលរួមថែទាំយ៉ាងសកម្ម ។ កសិករក៏មានប្រពៃណីសហការគ្នា ក្នុងការគ្រប់គ្រងធារាសាស្ត្រដោយខ្លួនឯង និងក្រោយមក ក៏ត្រូវបានរៀបចំជាលក្ខណៈក្រៅផ្លូវការពីឆ្នាំ ១៩៩៥ ដល់ ២០០០ ។ ប្រពៃណីសហការគ្នានេះ បានជួយឲ្យសហគមន៍សម្រេចជោគជ័យតាម ៣ របៀបគឺ៖ ទីមួយ សហគមន៍មានថ្នាក់ដឹកនាំដែលមានសមត្ថភាពស្រាប់ ក្នុងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ។ ទីពីរ កសិករមូលដ្ឋាន មានបទពិសោធន៍ក្នុងការបង្កើតលក្ខន្តិកៈសមស្របសម្រាប់សហគមន៍ ។ ទីបី កសិករយល់ដឹងពីសារៈសំខាន់នៃការចូលរួមរបស់ខ្លួន ។

**ជំនួយគាំទ្រពីខាងក្រៅ៖** FWUC អូរត្រែង ទទួលបានជំនួយទ្រទ្រង់ជាច្រើនពីក្រសួងធនធានទឹក អាជ្ញាធរឃុំ និងស្រុក និងកម្មវិធីស្បៀងអាហារពិភពលោក មានជាអាទិ៍ ការស្តារជួសជុល និងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ ជំនួយគាំទ្រដល់ការបង្កើតសហគមន៍ ការបណ្តុះបណ្តាល ធនធានហិរញ្ញវត្ថុសម្រាប់ជួយរ៉ាប់រងចំណាយក្នុងរយៈពេល២ឆ្នាំដំបូង ការពិគ្រោះយោបល់ការពង្រឹង លក្ខន្តិកៈ និងការដោះស្រាយទំនាស់ ។

ជំនួយពីខាងក្រៅ បានជួយកែលំអគុណភាពហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រតាមរយៈការស្តារជួសជុល និងបានជួយពង្រឹងចំណេះដឹង និងជំនាញរបស់កសិករ និងគណៈកម្មការតាមរយៈការបណ្តុះបណ្តាល និងការកសាងសមត្ថភាព ដែលធ្វើឲ្យអភិបាលកិច្ច និងការគ្រប់គ្រងនៅមូលដ្ឋានអាចដំណើរការល្អ ។ ម៉្យាងទៀត រដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋាន បន្តផ្តល់ជំនួយទ្រទ្រង់ជាបន្តបន្ទាប់ ដោយមិនធ្វើឲ្យប៉ះពាល់ដល់ស្វ័យភាពរបស់សហគមន៍ក្នុងការសម្រេចចិត្តនោះឡើយ ។

**ទីផ្សារ៖** ដោយសារកសិករមានទីផ្សារសម្រាប់ផលិតផលរបស់ខ្លួន ពួកគេទទួលបានប្រាក់ចំណូលច្រើនដែលអាចយកទៅបង់ថ្លៃសេវាប្រើប្រាស់ទឹក និងលើកកំពស់ជីវភាពរស់នៅ ។

កសិករអាចលក់ផលិតផលរបស់ខ្លួនទៅឯទីផ្សារ ឬលក់ទៅឲ្យឈ្មួញកណ្តាលដែលមកទិញដល់ចម្ការ ។ ជាទូទៅតំលៃលក់ដោយផ្ទាល់នៅទីផ្សារ ខ្ពស់ជាង ២ដង តំលៃលក់ទៅឲ្យឈ្មួញនៅចម្ការ ។ ប៉ុន្តែទោះយ៉ាងនេះក្តី កសិករចូលចិត្តលក់ផលិតផលទៅឲ្យឈ្មួញកណ្តាលដែលមកទិញដល់ចម្ការ ព្រោះពួកគេអាចលក់ផលិតផលបានទាំងអស់ភ្លាមៗ ។ វិធីនេះល្អសម្រាប់លំហូរសាច់ប្រាក់របស់កសិករ ហើយកសិករមិនបាច់បារម្ភពីការរក្សាទុកផលិតផល ឬការខាតបង់អ្វីទេ ។ ឈ្មួញកណ្តាលក៏សុខចិត្តបង់ថ្លៃឲ្យកសិករមុនពេលប្រមូលផលដែរ ដើម្បីជួយដោះស្រាយតម្រូវការចាយវាយរបស់កសិកររហូតដល់ពេលប្រមូលផល ។ ចំណុចល្អមួយទៀតនោះគឺឈ្មួញកណ្តាលក៏ព្រមទទួលធ្វើការប្រមូលផល និងដឹកជញ្ជូនផលិតផលទៅទីផ្សារដោយខ្លួនឯង ។ កសិករដែលទៅលក់ផលិតផលដោយផ្ទាល់នៅទីផ្សារ ត្រូវមានទំនាក់ទំនងជាប្រចាំជាមួយអ្នកលក់រាយ ដូច្នេះពួកគេត្រូវចំណាយទាំងពេលវេលា និងលុយកាក់ ហើយកសិករភាគច្រើនមិនជ្រើសយកជំរើសនេះទេ ។

ឈ្មួញកណ្តាលភាគច្រើនជាអ្នកមកពីក្រៅ ប៉ុន្តែមានខ្លះជាកសិករនៅមូលដ្ឋាន ។ ឈ្មួញកណ្តាល មកទិញផលិតផលនៅសហគមន៍នេះ ពីព្រោះវានៅជិតទីផ្សារមូលដ្ឋាន និងរាជធានីភ្នំពេញ ហើយមានផ្លូវល្អ ។ ម៉្យាងទៀត សហគមន៍នេះជាកន្លែងមួយនៃស្រុកគងពិសី ដែលមានដាំឪឡឹក និងត្រឡាចច្រើនជាងគេនៅរដូវប្រាំង ។

## សេចក្តីសន្និដ្ឋាន

ការសិក្សាស្រាវជ្រាវនេះបានរកឃើញថា ដើម្បីអនុវត្ត FWUC ឲ្យបានជោគជ័យ ត្រូវយកចិត្តទុកដាក់លើកត្តាចំនួន ៧ និងទំនាក់ទំនងរវាងកត្តាទាំងនោះ ។ ទំនាក់ទំនងទាំងនេះបង្កើតឲ្យមានជាកត្តាចាំបាច់ផ្សេងទៀត ដូចជា ទំនុកចិត្ត ភាពយុត្តិធម៌ ភាពជាម្ចាស់កម្មសិទ្ធិ និងការគោរពតាមលក្ខន្តិកៈសហគមន៍របស់កសិករ ដែលទាំងអស់នេះសំខាន់បំផុតសំរាប់ជួយឲ្យ FWUC ដំណើរការ ។

ជោគជ័យរបស់ FWUC ទាមទារការចូលរួមពីកសិករ ដែលកើតឡើង នៅពេលកសិករទទួលបានផលប្រយោជន៍ច្រើនពីប្រព័ន្ធ ដូចជា សន្តិសុខស្បៀង ឬចំណូលពីការលក់ផលដំណាំជាដើម ។ បើសិនគ្មានផលប្រយោជន៍ទាំងនេះទេ កសិករក៏មិនសូវមានទឹកចិត្តចូលរួមថែទាំប្រព័ន្ធធារាសាស្ត្រដែរ ។ ទីផ្សារក៏ជាកត្តាដ៏សំខាន់ ដើម្បីឲ្យកសិករទទួលបានផលប្រយោជន៍ច្រើនពីប្រព័ន្ធ ។ ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រមានគុណភាពល្អ ក៏ជាកត្តាសំខាន់ធានាឲ្យមានការផ្គត់ផ្គង់ទឹកគ្រប់គ្រាន់ និងទាន់ពេល ។ កត្តាសំខាន់មួយទៀត គឺអភិបាលកិច្ចមូលដ្ឋាន ពិសេសសមត្ថភាពដឹកនាំ និងការធ្វើសេចក្តីសម្រេចចិត្តរបស់គណៈកម្មការ ។

ជោគជ័យរបស់ FWUC ក៏ទាមទារជំនួយគាំទ្រពីខាងក្រៅក្នុងកម្រិតណាមួយពីសំណាក់រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងក្រុមប្រឹក្សាឃុំ និងស្រុក ។ ចរិតលក្ខណៈ និងស្ថានភាពរស់នៅជាក្រុមរបស់កសិករ ក៏សំខាន់ណាស់ដែរ ។ ជោគជ័យរបស់សហគមន៍នឹងកាន់តែបានល្អថែមទៀត ប្រសិនសហគមន៍ធ្លាប់មានប្រពៃណីសហការគ្នា ក្នុងការងារគ្រប់គ្រងធារាសាស្ត្រដោយខ្លួនឯង កសិករមានភាពស្រដៀងគ្នាក្នុងការរស់នៅ និងពឹងផ្អែកលើការដាំដុះដើម្បីទ្រទ្រង់ជីវភាព ។

## ឯកសារយោង

សូមមើលក្នុងឯកសារជាភាសាអង់គ្លេស ។